ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

**ជូនចំពោះ**

**ឯកឧត្តម ចាន់ វាសនា ទីប្រឹក្សាក្រសួងមុខងារសាធារណៈ និងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីសោកសង្រេងយ៉ាងក្រៃលែង ដោយបានទទួលដំណឹងថា ឧបាសិកា ហង់ ពិរុន ដែលត្រូវជាម្តាយបង្កើត ឯកឧត្តម ចាន់ វាសនា ទីប្រឹក្សាក្រសួង បានទទួលមរណភាពនៅថ្ងៃសៅរ៍ ១៤កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១៦:៣៥នាទី ក្នុងជន្មាយុ៩១ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្តនិងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ជ្រាលជ្រៅ ពោរពេញដោយក្តីសោកស្តាយជាអនេកប្បការជូនចំពោះ ឧបាសិកា ហង់ ពិរុន ដែលបានធ្វើមរណកាលលាចាកលោក លាចាកពីបុត្រធីតា និងក្រុមញាតិគ្រួសារជាទីស្រលាញ់។

ខ្ញុំសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ ឧបាសិកា ហង់ ពិរុន បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម និងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃសៅរ៍ ១៤កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

ព្រុំ សុខា

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងទាំងអស់មេត្តាជ្រាបថា ឧបាសិកា **ហង់ ពិរុន** ត្រូវជាម្តាយបង្កើត ឯកឧត្តម **ចាន់ វាសនា** ទីប្រឹក្សាក្រសួង បានទទួលមរណភាពនៅថ្ងៃសៅរ៍ ១៤កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១៦:៣៥នាទី ក្នុងជន្មាយុ៩១ឆ្នាំ ដោយជរាពាធ។

**ឯកឧត្តម ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នឹងអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១០:០០នាទីព្រឹក នៅផ្ទះលេខ ២៥បេ ផ្លូវបេតុង ក្រុម៤ ភូមិតាដៅ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានបំណងចូលរួមពិធីគោរពវិញ្ញាណក្ខន្ធនេះ អាចអញ្ជើញចូលរួមជាមួយ ឯកឧត្តមរដ្ឋមន្ត្រី ឬអញ្ជើញចូលរួមដោយផ្ទាល់ខ្លួនតាមពេលវេលាសមស្រប ដើម្បីចាប់មគ្គផលតាមកម្លាំងសទ្ធាជ្រះថ្លារៀងៗខ្លួន។

ថ្ងៃសៅរ៍ ១៤កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១

ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh